ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ
# ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីតម្រោងអភិវឌ្ឍក្រុងប៉ុកគោ

ឆ្នាំ ២០១៩

លេខ 2006
ថ្ងៃខែឆ្នាំ 9.7.19 10:30

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ"

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

## សម្រេច

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា ២.-**

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ អាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងរដ្ឋបាលខេត្តពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.៨៤.អនក្រ.បក.ចុះថ្ងៃព្រហ.១១រោច.ខែ.ជេស្ឋ...ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី.២៧.... ខែ.មិថុនា... ឆ្នាំ២០១៩
ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប៉ុកគោ

# ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប៉ុកគោ

## ចក្ខុវិស័យឆ្នាំ២០៣៥

# មាតិកា

ទំព័រ

**១-សេចក្ដីផ្ដើម** ..... ១

**២-ចក្ខុវិស័យ** ..... ៣

**២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម** ..... ៣

**២.២-ចក្ខុវិស័យ** ..... ៣

**៣-គោលបំណង និងគោលដៅ** ..... ៣

**៣.១-គោលបំណង** ..... ៣

**៣.២-គោលដៅ** ..... ៣

**៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអាទិភាពគម្រោងអភិវឌ្ឍក្រុងបូកគោ** ..... ៤

**៤.១-យុទ្ធស្រាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព** ..... ៤

*៤.១.១ -ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម* ..... ៤

*៤.១.២- យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី* ..... ៥

**៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍** ..... ១២

*៤.២.១-តំបន់ទេសចរណ៍* ..... ១៣

*៤.២.២-ផលិតផលទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានទេសចរណ៍* ..... ១៣

*៤.២.៣-ខ្សែទស្សនាកម្សាន្ត ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍* ..... ១៤

*៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស* ..... ១៤

**៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម** ..... ១៤

*៤.៣.១-អ័ក្សទេសចរណ៍-ពាណិជ្ជកម្ម* ..... ១៥

*៤.៣.២-ផ្លូវថ្នល់* ..... ១៥

*៤.៣.៣-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា* ..... ១៥

*៤.៣.៤-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌* ..... ១៦

*៤.៣.៥-ការផ្គត់ផ្គង់ទឹកស្អាត* ..... ១៦

**៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច** ..... ១៧

**៤.៥-យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន ធនធានធម្មជាតិ និងការអភិវឌ្ឍបៃតង** ..... ១៧

*៤.៥.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង* ..... ១៧

*៤.៥.២-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ* ..... ១៨

*៤.៥.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន* ..... ១៨

*៤.៥.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ* ..... ១៩

៤.៦-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ.......... ១៩

៤.៧-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន.......... ១៩

៥-ផែនការសកម្មភាព.......... ២០

៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម.......... ២០

៥.២-ការផ្សព្វផ្សាយ.......... ២០

៥.៣-ការអនុវត្តគម្រោងតាមវិស័យ.......... ២១

*៥.៣.១-ការអភិវឌ្ឍក្រុង.......... ២១*

*៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍.......... ២១*

*៥.៣.៣-ការដឹកជញ្ជូន.......... ២២*

*៥.៣.៤-ការគ្រប់គ្រងបរិស្ថាន.......... ២២*

*៥.៣.៥-ការគ្រប់គ្រងសំណល់រឹង.......... ២២*

*៥.៣.៦-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ.......... ២៣*

*៥.៣.៧-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត.......... ២៣*

*៥.៣.៨-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍.......... ២៣*

៥.៤-ការអនុវត្តផែនការរយៈពេលខ្លី មធ្យម និងវែង.......... ២៤

*៥.៤.១-ការអនុវត្តផែនការរយៈពេលខ្លី.......... ២៤*

*៥.៤.២-ការអនុវត្តរយៈពេលមធ្យម.......... ២៤*

*៥.៤.៣-ការអនុវត្តរយៈពេលវែង.......... ២៤*

៥.៥-គម្រោងអាទិភាព.......... ២៤

៦-ធនធានហិរញ្ញវត្ថុ.......... ២៥

៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ.......... ២៥

៧.១-យន្តការ.......... ២៥

៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត.......... ២៥

៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍.......... ២៦

៨-សេចក្តីសន្និដ្ឋាន.......... ២៧

ឯកសារឧបសម្ព័ន្ធ.......... ២៨

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ**កម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ខេត្តកំពតស្ថិតនៅទិសនិរតីក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានរមណីយដ្ឋានឋានសួគ៌បូកគោ និងជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ជាគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិល្អឯកពេញនិយមបំផុតនៅព្រះរាជាណាចក្រកម្ពុជា។ ខេត្តមានព្រំប្រទល់ជាប់នឹងសមុទ្រ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកែប និងប្រទេសវៀតណាម។ សក្តានុពលធនធានធម្មជាតិជាច្រើន ដូចជា ព្រៃភ្នំ សត្វព្រៃ ទឹកធ្លាក់ កោះ សត្វសមុទ្រ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង ឆ្នេរខ្សាច់ ស្រែអំបិល រ៉ែថ្មកំបោរ ដីកសិកម្ម និងមានសក្តានុពលទេសចរណ៍ធម្មជាតិ ជាច្រើនមានដូចជា សំណង់បេតិកភណ្ឌក្រុងកំពត រមណីយដ្ឋានទេសចរណ៍ធម្មជាតិឋានសួគ៌បូកគោ ល្អាងភ្នំកំពង់ត្រាច ព្រែកត្នោត ភ្នំសិដាអោន ទឹកឈូ ប្រាសាទភ្នំឈ្នោក សួនសត្វទឹកឈូ ទឹកធ្លាក់បីថ្នាក់ ទំនប់ប្រទាក់ក្រឡា ទំនប់ម្លិច និងរមណីយដ្ឋានភ្នំដូង សហគមន៍ទេសចរណ៍ព្រែកត្នោត ត្រពាំងសង្កែ កែបថ្មី សហគមន៍ទេសចណ៍លក និងតំបន់កម្សាន្តឆ្នេរសមុទ្រព្រែកអំពិល។ សក្តានុពលទេសចរណ៍ទាំងអស់នេះបានធ្វើឱ្យខេត្តកំពតមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សស្ទើរគ្រប់វិស័យ ដូចជា វិស័យសំណង់ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម រ៉ែ ថាមពល សេដ្ឋកិច្ច ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។

ដោយពិនិត្យទៅលើសក្តានុពល ក៏ដូចជាប្រវត្តិសាស្ត្រ ក្រុមការងារបច្ចេកទេសនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះធ្វើការសិក្សាស្រាវជ្រាវក្នុងភូមិសាស្ត្រឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ឃើញថា ទីតាំងនេះជាអតីតទីក្រុងប្រវត្តិសាស្ត្រនៅឆ្នាំ ១៩២៥-១៩៦២ ដ៏មានសក្តានុពល ដែលមានអាកាសធាតុត្រជាក់ល្អបរិសុទ្ធ ទេសភាពធម្មជាតិតំបន់ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា និងជាគោលដៅទេសចរណ៍

ប្រណីតកម្រិតខ្ពស់ និងមានហេដ្ឋារចនាសម្ព័ន្ធជាទីក្រុងរដ្ឋបាលដែលបានបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ដូចជា អគាររដ្ឋបាល ព្រះរាជដំណាក់ លំនៅឋាន អគារសេវាកម្ម សាលាក្រុង ប្រៃសណីយ៍ អគារសុរិយោដី សាលារៀន វត្តអារាម ព្រះវិហារកាតូលិក គិលានដ្ឋាន ប៉ុស្តិ៍នគរបាល ទីបញ្ជាការយោធា សណ្ឋាគារ ស្ថានីយទឹកស្អាត ស្ថានីយ អគ្គិសនី ទំនប់ទឹកបារាំង។ល។

ផ្អែកតាមរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែល មានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិជាសេនាធិការ បានផ្តួចផ្តើម សិក្សានិងរៀបចំប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានទីតាំងស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" នៃភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ មានផ្ទៃក្រឡាប្រមាណ ២៧ ៩៤៣ ហិកតា ស្មើនឹង ១៨,០៩% នៃផ្ទៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ទំហំ ១៥៤ ៥៤២ ហិកតា អនុលោមតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ និងអនុក្រឹត្យ លេខ ១៧១ អនក្រ.បក ចុះ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍន៍ក្រុងបូកគោប្រកបដោយចីរភាព។

ប្លង់គោលប្រើប្រាស់ដីនេះត្រូវបានកសាងឡើងដោយការសិក្សាច្បាស់លាស់លើកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជនជាដើម។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោនេះ ត្រូវបានរៀបចំឡើងដោយមានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសអភិរក្សតំបន់ទីក្រុងប្រវត្តិសាស្ត្រ។

## ២-ចក្ខុវិស័យ

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគ ទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្រប តាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី “សៀវភៅ ស ដីធ្លី” និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ គឺសំដៅរៀបចំនិងអភិវឌ្ឍ **«ភ្នំបូកគោ ជាក្រុងឆ្លាតវៃ ទេសចរណ៍ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា»** តាមរយៈការជំរុញ ÷ ១).កំណត់គោលនយោបាយ និងបទដ្ឋានគតិយុត្តបង្កើតជាក្រុង សម្រាប់លំនៅឋាន សម្រាកលំហែកម្សាន្ត សិក្សា ការងារ និងធុរកិច្ច ប្រកបដោយសុខភាព គុណភាពបរិស្ថានល្អ និងជាទិសដៅទេសចរណ៍ដ៏ប្រណីតកម្រិតខ្ពស់ សម្រាប់ការទាក់ទាញ និងប្រកួតប្រជែងក្នុងតំបន់និងអន្តរជាតិ ២). ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ថែរក្សាប្រភពទឹកធម្មជាតិ ទេសភាព និងអាកាសធាតុភ្នំ-សមុទ្រ ៣).កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន លំហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសមាហរណកម្មតភ្ជាប់ក្នុងតំបន់ ៤).ទាក់ទាញលើកទឹកចិត្ត និងគាំទ្រដល់ការវិនិយោគសាធារណៈ និងឯកជន ដើម្បីអភិវឌ្ឍធុរកិច្ច អភិវឌ្ឍផលិតផលទេសចរណ៍សម្បូរបែបប្រកបដោយគុណភាពខ្ពស់ និងជំរុញកំណើនសេដ្ឋកិច្ច និង ៥).អភិបាលកិច្ចល្អ និងអភិវឌ្ឍធនធានមនុស្ស។

## ៣-គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលបំណង និងគោលដៅ ដូចខាងក្រោម÷

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលបំណង “ធានាការគ្រប់គ្រង និងអភិបាលកិច្ចទីប្រជុំជនភ្នំបូកគោឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយគុណភាព តុល្យភាព សមធម៌ និងចីរភាព”។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលដៅ÷

- ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ បរិស្ថាន និងធនធានធម្មជាតិ ទេសភាព និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា

- គ្រប់គ្រងការប្រើប្រាស់ដី និងនគរូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព ចីរភាព គុល្យភាព និងសមាហរណកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ចទាក់ទាញ គាំទ្រដល់ការវិនិយោគសាធារណៈនិងវិស័យឯកជន ដើម្បីសមធម៌សង្គម និងផ្តល់ការងារ
- គ្រប់គ្រងជីវវដ្ត បរិស្ថាន និងធនធានធម្មជាតិ ជំរុញអភិវឌ្ឍន៍បៃតង និងការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ជាក្រុងគោលដៅទេសចរណ៍ស្អាត ឆ្លាតវៃ គ្មានថង់ប្លាស្ទិក និងមេដែកឆក់ប្រកបដោយគុណភាព និងភាពប្រកួតប្រជែងខ្ពស់នៅភាគខាងត្បូងអាស៊ាន
- លើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយ និងឆ្លើយតបបានល្អតាមតម្រូវការរបស់ប្រជាពលរដ្ឋទូទៅ និងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សគម្រោងអភិវឌ្ឍក្រុងបូកគោ

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ចនិងការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម÷

### ៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

៤.១.១ - ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម

- រៀបចំបទដ្ឋានគតិយុត្ត និងបច្ចេកទេស សម្រាប់បង្កើតនិងគ្រប់គ្រងក្រុងបូកគោ ជាក្រុងឆ្លាតវៃ ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំហេដ្ឋារចនាសម្ព័ន្ធនិងសោភ័ណភាពក្រុងមាន ចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺ ផ្លាកសញ្ញាចរាចរ ឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ គុណភាព បរិស្ថានល្អ សមស្របជាក្រុងទេសចរណ៍ប្រវត្តិសាស្ត្រ ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំកសាងមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លំហសាធារណៈ កំណត់ប្រភេទនិងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយសុខភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កសាងបណ្តាញទឹកស្អាត បណ្តាញអគ្គិសនី គ្រប់គ្រងសំណល់រឹងនិងរាវ តាមលក្ខណៈបច្ចេកទេស និងប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភ័ណភាពក្រុង

- រៀបចំនិងកំណត់រចនាបទអគារ ពាណិជ្ជអគារ និងកំណត់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវនិងតាមតំបន់ឱ្យមានសណ្ដាប់ធ្នាប់និងសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ ប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ ស្របតាមទីតាំងភូមិសាស្ត្រ
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍរូបវន្ត ជាពិសេសបណ្ដាញផ្លូវ ស្ថានីយចម្រោះទឹកស្អាត ប្រព័ន្ធលូនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ ដោយជំរុញការអភិវឌ្ឍ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខា និងសេវាកម្មទីក្រុងជាមុន
- ពង្រឹងសមត្ថភាពមន្ត្រីធ្វើផែនការអភិវឌ្ឍ និងគ្រប់គ្រងការអភិវឌ្ឍ ជាពិសេសប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្ត ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តន៍ការងាររៀបចំដែនដីនិងនគរូបនីយកម្ម។

៤.១.២- យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី

ផ្អែកលើអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការកំណត់តំបន់ការពារធម្មជាតិ អនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១០ ស្ដីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" គម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់។ ឧទ្យានជាតិព្រះមុនីវង្សនេះមានផ្ទៃដីសរុប ១៥៤ ៤៥៨ ហិកតា ត្រូវបានកំណត់ជាប្រភេទដីអាចសាងសង់បានមានចំនួន ២៧ ៩៤៣ ហិកតា ស្មើនឹង ១៨,០៩% នៃផ្ទៃដីឧទ្យាន និងប្រភេទដីកម្រិតការសាងសង់មានចំនួន ១២៦ ៥១៥ ហិកតា ស្មើនឹង ៨១,៩១% នៃផ្ទៃដីឧទ្យានទាំងមូល។ ផ្ទៃដីដែលបានធ្វើអនុប្រយោគ និងបានប្រគល់ជូនក្រុមហ៊ុន សុខា អូតែល ចំនួន ១៨ ៩៨៧ ហិកតា អនុក្រឹត្យលេខ ៥៩ អនក្របក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១១ ស្ដីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

ក)- ប្រភេទដីកម្រិតការសាងសង់

ផ្អែកតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដាក់ឱ្យប្រើប្រាស់ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ និងអនុក្រឹត្យលេខ ៥៩ អនក្របក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១ស្ដីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព អនុក្រឹត្យស្ដីពីការធ្វើអនុប្រយោគបូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដីតំបន់ប្រើប្រាស់ដោយចិរភាពនៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១១ និងបទដ្ឋានគតិយុត្តជាធរមាន ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជាតំបន់ ដូចខាងក្រោម÷

១. តំបន់ការពារនៃឧទ្យានជាតិព្រះមុនីវង្ស÷ មានផ្ទៃដីទំហំ ៨១ ២៥៧ ហិកតា ស្មើនឹង ៥២,៦១% នៃផ្ទៃដីឧទ្យានព្រះមុនីវង្សបូកគោ នៅសល់ក្រោយពីផ្ដល់ឱ្យទៅក្រុមហ៊ុន សុខាអូតែល និងរៀបចំជាគម្រោង

អភិវឌ្ឍក្រុងបូកគោ។ តាមការចុះសិក្សានៅទីតាំងជាក់ស្តែង តំបន់នេះមានរូបភាពប្រើប្រាស់ជាទីក្រុងប្រវត្តិសាស្ត្រ ភ្នំ ធនធានទឹក ព្រៃឈើ ផ្លូវគមនាគមន៍ និងតំបន់កសិកម្ម។

២. តំបន់ធនធានទឹក÷ រួមមានអូរ ប្រឡាយ ត្រពាំង ស្ទឹង អាងស្តុកទឹក មានផ្ទៃទឹកប្រមាណ ១ ០៩៤ ហិកតា ស្មើនឹង ០,៧១% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស (មិនគិតតំបន់ធនធានទឹកដែលមាននៅក្នុងដីក្រុមហ៊ុន សុខា អូតែល)។ តំបន់នេះ ជាសក្តានុពលដ៏សំខាន់ដែលត្រូវស្តារ ការពារ និងថែរក្សា ដើម្បីប្រើប្រាស់សម្រាប់គាំទ្រដល់ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធរំដោះទឹកជំនន់ អាងប្រព្រឹត្តកម្មទឹកកខ្វក់តាមបែបធម្មជាតិ ផ្លូវទឹក និងវិស័យកសិកម្ម ព្រោះផលិតផលកសិកម្មធម្មជាតិនេះជាធាតុសំខាន់ក្នុងការផ្គត់ផ្គង់ជាអាហារ សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

៣. តំបន់កសិកម្ម÷ ដីកសិកម្មជាសួនសត្វ មានទំហំផ្ទៃដីប្រមាណ ១៦០ ហិកតា ស្មើនឹង ០,១០% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស។ តំបន់នេះត្រូវ÷

- រក្សាផ្ទៃដីកសិកម្ម ដែលមានសក្តានុពល សម្រាប់ដំណាំស្រូវ ការចិញ្ចឹមសត្វ ដាំបន្លែ និងវារីវប្បកម្ម ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមប្លង់គោលប្រើប្រាស់ដីនេះ
- ធ្វើផែនការគ្រប់គ្រងផ្ទៃដីកសិកម្មដោយធ្វើការកំណត់ និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់
- អនុវត្តផែនការពង្រីកក្រុងតាមបច្ចេកទេសទំនើប ដើម្បីកាត់បន្ថយជាអតិបរមាដល់ផ្ទៃដីកសិកម្មដែលបានបម្រុងទុក និងពង្រីកដីកសិកម្មបន្ថែមនៅតាមទីជម្រាលភ្នំ។

៤. តំបន់ដីក្រុមហ៊ុន សុខា អូតែល÷ តំបន់នេះមានទំហំប្រមាណ ១៨ ៩៨៧ ហិកតា ស្មើនឹង ១២,២៩% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស។ ទីតាំងនេះត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុន សុខា អូតែល បង្កើតជាមជ្ឈមណ្ឌលទេសចរណ៍ ការស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការអភិវឌ្ឍដី។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ១០% ថ្លាតម្លាតអគារខាងមុខយ៉ាងតិច ១០ ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខ កម្ពស់អគារអតិបរមាស្មើនឹង ៨ ម៉ែត្រ សួនច្បារដែលអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច ៦៥% នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច ១ ដើម សម្រាប់ផ្ទៃក្រឡាដីឡូត៍ ៤៩ ម៉ែត្រក្រឡា។

ខ)- ប្រភេទដីអាចសាងសង់បាន

គម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានបែងចែកជា ៨ ទីតាំងធំៗ ហើយទីតាំងនីមួយៗត្រូវបានកំណត់ការប្រើប្រាស់ដីជាតំបន់ ហើយតំបន់នីមួយៗត្រូវមានបទប្បញ្ញត្តិនៃការប្រើប្រាស់ផ្សេងៗគ្នា។

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជា ៩ តំបន់សំខាន់ៗ រួមមាន តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់ទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាកម្មសាធារណៈ តំបន់លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ថ្លាគម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកជាតំបន់ប្រើប្រាស់ដី ដូចខាងក្រោម៖

១. តំបន់លំនៅឋាន÷ តំបន់នេះស្ថិតនៅគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង នៃគម្រោងអភិវឌ្ឍក្រុងបូកគោ មានផ្ទៃដីប្រមាណ ៣ ៣៩០ ហិកតា ស្មើនឹង ៣៧,៨៥% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ។ តំបន់លំនៅឋានត្រូវបានបែងចែកជាតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប តំបន់លំនៅឋានដែលមានកម្ពស់មធ្យម តំបន់លំនៅឋានមានកម្ពស់ខ្ពស់ និងតំបន់លំនៅឋានចម្រុះ។ តំបន់នេះត្រូវបានកំណត់និងបែងចែកជា៖

- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវកំណត់÷
    - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
    - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ១,០
    - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
    - សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
    - ថ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៤ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ២ ម៉ែត្រ
    - ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
    - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
    - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។
- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវកំណត់÷
    - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
    - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ១,៥
    - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
    - សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
    - ថ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៤ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ២ ម៉ែត្រ

- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៣ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានកម្ពស់ខ្ពស់ត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៨ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៣,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានចម្រុះត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ១០ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៤ ម៉ែត្រ

- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

២. តំបន់ពាណិជ្ជកម្ម÷ តំបន់នេះមានផ្ទៃដីប្រមាណ ៨២១ ហិកតា ស្មើនឹង ៩,១៧% នៃផ្ទៃដីអាចសាងសង់បានក្នុងតំបន់គម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតនៅគម្រោងទី ១ និងទី ៣ ដល់ទី ៨ និងត្រូវបែងចែកជាតំបន់ពាណិជ្ជកម្មជាផ្សារ និងតំបន់ពាណិជ្ជកម្មចម្រុះ ដែលត្រូវជំរុញអភិវឌ្ឍលម្ហសាធារណៈ និងផ្ទៃបៃតងឱ្យបានសមស្រប។ តំបន់នេះត្រូវបានកំណត់និងបែងចែកជា៖

- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ពាណិជ្ជកម្មជាផ្សារ ត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៦០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍សរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៣ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
  - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ៥០ ម៉ែត្រការ៉េ។
- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ពាណិជ្ជកម្មចម្រុះ ត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៧០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ២០% នៃផ្ទៃដីឡូត៍សរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៣ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
  - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ៥០ ម៉ែត្រការ៉េ។

៣. តំបន់ចម្រុះ÷ តំបន់នេះមានផ្ទៃដីប្រមាណ ៣៨០ ហិកតា ស្មើនឹង ៤,២២% នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅក្នុងគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង ដូចបានកំណត់ក្នុងផែនទី លាយឡំក្នុងតំបន់លំនៅឋាន តំបន់ទេសចរណ៍ និងតំបន់ពាណិជ្ជកម្ម មានមុខងារប្រើប្រាស់ច្រើនយ៉ាង ដូចជា សិប្បកម្ម ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និងសេវាកម្មផ្សេងៗ ។ តំបន់នេះត្រូវបានយកចិត្តទុកដាក់ដោយធានាបាននូវបរិស្ថានល្អ និងរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ចម្រុះត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- កំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៧០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៤. តំបន់ដឹកជញ្ជូន÷ តំបន់នេះមានផ្ទៃដីប្រមាណ ៦៤៤ ហិកតា ស្មើនឹង ៧,១៧% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ រួមមាន ប្រព័ន្ធផ្លូវ និងចំណតរថយន្តផ្សេងៗ។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ដឹកជញ្ជូនត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់

ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៥. តំបន់ទេសចរណ៍÷ តំបន់នេះមានផ្ទៃដីប្រមាណ ៨៥៦ ហិកតា ស្មើនឹង ៩,៥៦% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតនៅក្នុងគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង លើកលែងតែក្នុងគម្រោង

ទី ៥។ តំបន់ទេសចរណ៍ត្រូវរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ទេសចរណ៍ត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- កំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៦. តំបន់រដ្ឋបាលនិងសេវាសាធារណៈ÷ តំបន់នេះមានផ្ទៃដីប្រមាណ ៩៩៥ ហិកតា ស្មើនឹង ១១,១១% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតក្នុងគម្រោងទី ១ ទី ២ ទី ៥ ដល់ទី ៨។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់រដ្ឋបាលនិងសេវាសាធារណៈត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនិងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៤ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៧. តំបន់លំហសាធារណៈ និងផ្ទៃបៃតង÷ សួនច្បារសាធារណៈ មានផ្ទៃដីប្រមាណ ១ ១០២ ហិកតា ស្មើនឹង ១២,៣០% នៃផ្ទៃដីដែលអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង។ ក្រៅពីនេះ ផ្ទៃបៃតងជាតំបន់ទ្រនាប់ តំបន់កសិកម្ម និងតំបន់ការពារ ស្ថិតក្នុងតំបន់កម្រិតការសាងសង់ មានប្រមាណ ១២៥ ៤២១ ហិកតា ស្មើនឹង ៨០,២០% នៃផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំហសាធារណៈ ត្រូវកំណត់÷

- សំណង់សាធារណៈត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ

- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ០,៣
- សួនច្បារសាធារណៈ និងដាំដើមឈើកំណត់បង្ហាញអំពីអត្តសញ្ញាណទីតាំងភូមិសាស្ត្រ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវរៀបចំចំណតរថយន្តសម្រាប់សាធារណៈ
- ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការ និងជនងាយរងគ្រោះ។

៨. តំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស÷ តំបន់នេះមានផ្ទៃដីទំហំប្រមាណ ៦៣៧ ហិកតា ស្មើនឹង ៧,១១% នៃផ្ទៃដីដែលអាចសាងសង់បាននៃគម្រោងអភិវឌ្ឍក្រុងបូកគោ។ តំបន់នេះ រួមមាន ស្ថានីយចម្រោះទឹកស្អាត អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងទីលានទុកដាក់សំរាម។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៤ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

គម្រោងអភិវឌ្ឍ និងសាងសង់ក្នុងប្រភេទដីអាចសាងសង់បាននេះ តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុនស្របតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៥ ស្ដីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៨ ស្ដីពីការអភិវឌ្ឍដី។

## ៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍទេសចរណ៍តំបន់ ក៏ដូចជានៅទូទាំងប្រទេសកម្ពុជា។ តំបន់អភិវឌ្ឍក្រុងបូកគោមានសក្ដានុពលទេសចរណ៍ជាច្រើន ដូចជា ធនធានធម្មជាតិលើភ្នំ ឆ្នេរសមុទ្រ ព្រៃឈើ សត្វព្រៃ ទេសភាព អាកាសធាតុ និងតំបន់រមណីយដ្ឋានទេសចរណ៍នានា ជាពិសេសរមណីយដ្ឋានទេសចរណ៍ឋានសួគ៌បូកគោ និងរមណីយដ្ឋានទេសចរណ៍ក្នុងខេត្តជាច្រើនទៀត ហើយជាគោលដៅទេសចរណ៍ពេញនិយមសម្រាប់ការស្នាក់នៅ និងលំហែកម្សាន្ត។

គម្រោងអភិវឌ្ឍក្រុងបូកគោនេះ បានតភ្ជាប់ជាមួយតំបន់ឆ្នេរដែលស្ថិតនៅក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូង ជាតារាវៈនាទិសនិរតីនៃប្រទេសកម្ពុជា រួមមាន ខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង ដែលជាប៉ូលទេសចរណ៍ដ៏មានសារៈសំខាន់។ បច្ចុប្បន្ន ភាពល្បីល្បាញនៃភ្នំបូកគោ បានបំពេញតួនាទីស្នូលក្នុងការជម្រុញការអភិវឌ្ឍទេសចរណ៍តំបន់ភ្នំ ភ្ជាប់ជាមួយឆ្នេរសមុទ្រ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ផ្នែកឯកជន រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ គ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍វប្បធម៌ និងធម្មជាតិ ត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍នៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋាន គឺជាអាទិភាព។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ រួមមាន÷

៤.២.១- តំបន់ទេសចរណ៍

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍសំណង់ស្ថាបត្យកម្មលក្ខណៈខ្មែរ វប្បធម៌ សាសនា ដោយផ្សាភ្ជាប់នឹងទេសភាពវប្បធម៌ធម្មជាតិមានព្រៃឈើ សមុទ្រនិងភ្នំ
- ជំរុញអនុវត្តសេចក្តីថ្លែងការណ៍បូកគោ ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការអភិវឌ្ឍទីក្រុងតំបន់ឆ្នេរសមុទ្រប្រកបដោយនិរន្តរភាព
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- បង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងផលិតផលទេសចរណ៍ រួមមាន ការកម្សាន្តរមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិពរណ៍ផលិតផលក្នុងស្រុក
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សាររាត្រី លំនៅឋានទេសចរណ៍ បង្កភាពងាយស្រួលដល់ភ្ញៀវទេសចរ
- កែលម្អ និងរៀបចំផ្លូវមេ ផ្លូវដឹកជញ្ជូន ផ្លូវសម្រាប់យានយន្ត ផ្លូវថ្មើរជើង និងបណ្តាញបៃតង ធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ ពិសេសនៅតាមកន្លែងកម្សាន្ត និងកន្លែងស្នាក់នៅ
- លើកកម្ពស់អនាម័យចំណីអាហារ និងប្រព័ន្ធត្រួតពិនិត្យស្តង់ដារ។

៤.២.២- ផលិតផលទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានទេសចរណ៍

- ជំរុញការរៀបចំអភិវឌ្ឍន៍ផលិតផលទេសចរណ៍ធម្មជាតិតាមព្រៃភ្នំ អភិវឌ្ឍការធ្វើដំណើរតាមខ្សែកាបស្ពានយោលទេសចរណ៍ក្នុងព្រៃឈើ ដើម្បីគយគន់ព្រៃឈើ សមុទ្រ ព្រះអាទិត្យរះ លិច ហោះផ្លាយលើអាកាស ទេសភាពលំនៅឋាន ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងទឹកធ្លាក់

- រៀបចំសួនច្បារកម្សាន្ត និងទេសភាពធម្មជាតិ សម្រាប់ភ្ញៀវទេសចរ ប្រជាជននៅមូលដ្ឋាន និងកុមារ មនុស្សវ័យចាស់
- បង្កើតចំការកង្ហារលើភ្នំសម្រាប់វិស័យថាមពល និងទស្សនាកម្សាន្ត
- រៀបចំឱ្យមានតំបន់ទេសចរណ៍សម្រាកកម្សាន្តបឹងហ្គាឡូ តាមមាត់ទឹក និងតាមជម្រាលភ្នំ
- អភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ សាសនា ជាព្រលឹងរបស់ភ្នំ របស់ជាតិ និងតំបន់
- អភិវឌ្ឍទេសចរណ៍ទេសភាពតាមជម្រាលភ្នំ ការដាំដើមឈើ-ផ្កា ការធ្វើកសិកម្មសេរីរាង្គមានស្ពៃបូកគោ ប៉េងប៉ោះ ផ្កាបំពង់ឡោម ចំការតែ
- អភិវឌ្ឍឱ្យមានស្ពាន និងផ្លូវសម្រាប់ដើរលម្ហែកាយ និងស្រូបខ្យល់អាកាសតាមព្រៃភ្នំ
- អភិវឌ្ឍផ្ទះលម្ហែសម្រាក វីហ្សេត ភោជនីយដ្ឋាន ក្លឹបកម្សាន្ត កន្លែងហាត់កីឡា តាមទីជម្រាលភ្នំ ការប្រណាំងទូកក្នុងបឹងលើភ្នំ។

៤.២.៣-ខ្សែទស្សនាកម្សាន្ត ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍
- រៀបចំកម្មវិធីបុណ្យជាតិ និងព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍។

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស

- បណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។

### ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ឧទ្យានជាតិព្រះមុនីវង្ស ស្ថិតក្នុងខេត្តចំនួន ៣ គឺ ខេត្តកំពត ព្រះសីហនុ និងខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នឧទ្យាននេះប្រើផ្លូវសំខាន់មួយភ្ជាប់ពីផ្លូវជាតិលេខ ៣ មកកាត់តាមរមណីយដ្ឋានឋានសួគ៌បូកគោ និងផ្លូវនៅជុំវិញលើកំពូលភ្នំ។ ហេដ្ឋារចនាសម្ព័ន្ធគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវពង្រឹង និងលើកកម្ពស់សម្រាប់វិស័យទេសចរណ៍ សេដ្ឋកិច្ច បរិស្ថាន និងសង្គម រួមមាន÷

៤.៣.១- អ័ក្សទេសចរណ៍-ពាណិជ្ជកម្ម

- តភ្ជាប់ផ្លូវមេពីផ្លូវជាតិលេខ ៣ ត្រង់ចំណុចច្រកចូលរមណីយដ្ឋានឋានសួគ៌បូកគោ ឆ្លងកាត់ឧទ្យានជាតិព្រះមុនីវង្ស កាត់តាមរមណីយដ្ឋានឋានសួគ៌បូកគោ មកគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង និងតភ្ជាប់ទៅផ្លូវជាតិលេខ ៤ ត្រង់ចំណុចជិតភូមិសាស្ត្រស្ទឹងប្រាល
- សាងសង់ផ្លូវមេតភ្ជាប់សំខាន់ ចេញពីគម្រោងអភិវឌ្ឍក្រុងបូកគោក្នុងទីតាំងគម្រោងទី ១ ភ្ជាប់ទៅផ្លូវជាតិលេខ ៤ ត្រង់ចំណុចទីប្រជុំជនស្រុកកំពង់សិលា ខេត្តព្រះសីហនុ
- សាងសង់ផ្លូវមេតភ្ជាប់រវាងតំបន់រមណីយដ្ឋានឋានសួគ៌បូកគោ ទៅនឹងគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង។

៤.៣.២- ផ្លូវថ្នល់

យុទ្ធសាស្ត្រស្តារអភិវឌ្ឍន៍ និងការពារបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនៃគម្រោងអភិវឌ្ឍក្រុងបូកគោមានដូចខាងក្រោម÷

- ស្តារនិងជួសជុល និងពង្រីកផ្លូវជាតិលេខ ៣២ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ និងប្រើប្រាស់សម្រាប់ទេសចរណ៍ ពាណិជ្ជកម្ម
- រៀបចំកសាង និងកែលម្អផ្លូវក្នុងក្រុងឱ្យមានគុណភាព សុវត្ថិភាព និងសោភ័ណភាព ស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំចំណតរថយន្តសាធារណៈឱ្យស្របតាមបទដ្ឋានទីក្រុងទេសចរណ៍ស្អាត
- សាងសង់ផ្លូវក្រវាត់ក្រុងតភ្ជាប់គម្រោងទីតាំងអភិវឌ្ឍទាំង ៨ ទីតាំង ដើម្បីងាយស្រួលធ្វើចរាចរនិងបញ្ចៀសការកកស្ទះចរាចរណ៍
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ តភ្ជាប់ផ្នែកកណ្តាលក្រុង ទៅកាន់ភាគខាងជើង និងភាគខាងត្បូងក្រុង ជាពិសេសតំបន់រមណីយដ្ឋានឋានសួគ៌បូកគោ ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ។

៤.៣.៣- ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- សិក្សា និងរៀបចំចំការកង្ហារអគ្គិសនីសម្រាប់ជាប្រភពថាមពលបម្រើដល់តំបន់
- ធ្វើឱ្យប្រសើរឡើង និងអភិវឌ្ឍវិស័យថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ប្រជាជននៅក្នុងក្រុង
- បន្ត និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់យានយន្តប្រើអាគុយ។

៤.៣.៤-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- រៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈនិងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិត ស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន ស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- បង្កើតមជ្ឈមណ្ឌលថែទាំសុខភាព ថែទាំវេជ្ជសាស្ត្រ និងខ្យល់អាកាសធម្មជាតិ។

៤.៣.៥-ការផ្គត់ផ្គង់ទឹកស្អាត

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោដោយផ្ទាល់។ អាជ្ញាធរខេត្ត ក្រុង និងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំប្រព័ន្ធផ្គត់ផ្គងទឹកមេ ឱ្យបានមុនការសាងសង់សំណង់សំណង់ផ្សេងៗ និងពង្រីកបន្ថែមបណ្តាញចែកចាយដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ តម្រូវការសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់គម្រោងអភិវឌ្ឍក្រុងបូកគោគឺមានដូចខាងក្រោម÷

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដានប្រភពទឹក ដើម្បីធានានូវបរិមាណទឹកស្អាតពីអាងស្តុកទឹក
- សិក្សាប្រភពទឹកផ្សេងៗ ពិសេសប្រភពទឹកបានមកពីផ្ទៃរងទឹកភ្លៀង របស់អាងស្តុកទឹកទាំងពីរន្លែងរបស់ក្រុង និងធានាថាមិនមានការបំពុល ដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់ក្រុង
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស។
- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។

## ៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះជាពិសេសប្រជាជនដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ជម្រុញឱ្យសហគមន៍ទទួលបានការគាំទ្រ និងលើកទឹកចិត្តពីផ្នែកសាធារណៈ សង្គមស៊ីវិល និងសេវាកម្មសុខភាព
- ជម្រុញការអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទ ឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព
- សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យបានការរស់នៅរបស់ប្រជាជនក្នុងតំបន់ប្រកបដោយសន្តិសុខ និងសុវត្ថិភាព។

## ៤.៥-យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន ធនធានធម្មជាតិ និងការអភិវឌ្ឍបៃតង

៤.៥.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

ទីលានចាក់សំរាមរបស់គម្រោងអភិវឌ្ឍក្រុងប្លុកគោ បានរៀបចំចំនួន ២ ទីតាំង ស្ថិតនៅផ្នែកខាងលិចក្រុងមួយកន្លែង និងខាងកើតក្រុងមួយកន្លែងទៀត និងមានចំងាយ ៥ គីឡូម៉ែត្រ ពីទីប្រជុំជនក្រុង។ ទីតាំងទាំងពីរនេះមានទំហំនិងចំងាយសមស្របសម្រាប់ទុកដាក់សំរាម។ ដូចនេះ ដើម្បីគ្រប់គ្រងសំណល់រឹងឱ្យបានល្អ សម្រាប់ទីតាំងទាំងពីរនេះ ត្រូវមានយន្តការ និងបទដ្ឋានបច្ចេកទេសដូចខាងក្រោម÷

- រៀបចំបង្កើតទីលានចាក់សំរាមដោយមានការអនុញ្ញាត និងគោរពតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងបរិស្ថាន
- បង្កើនការផ្សព្វផ្សាយដល់ប្រជាជនពីការញែកសំរាម ហើយអាចពង្រីកបន្ថែមនៅតាមសាលា និងទីសាធារណៈផ្សេងៗទៀត
- ផ្តល់លេខក្ខដធុងញែកសំរាមតាមពិណ ឬថង់សំរាមស្រាលៗដល់អ្នករើសសំរាម
- ជំរុញការសហការរវាងកន្លែងគរសំរាមមានស្រាប់ ដើម្បីញែក និងកាត់បន្ថយបរិមាណសរីរាង្គនៃសំណល់
- អ្នករើសសំរាមអាចទទួលបានវគ្គបណ្តុះបណ្តាល បង្កើនចំណេះដឹងស្វែងយល់ពីកាកសំណល់ដើម្បីផលិតសម្ភារៈ ធ្វើឱ្យការងារកាន់តែល្អប្រសើរសម្រាប់អ្នករើសសំរាមជាមួយនឹងទីកន្លែងធ្វើការសមរម្យនៅក្នុងរោងដែលមានខ្យល់ចេញចូលល្អ ដើម្បីចៀសវាងបានពីតំបន់មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ
- ផ្តល់សម្ភារៈធ្វើការប្រកបដោយសុវត្ថិភាព និងទុនសម្រាប់ការបណ្តុះបណ្តាល
- បង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង

- ជំរុញឱ្យមានការអនុវត្តគោលការណ៍ ការកាត់បន្ថយការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង បង្កើតគម្រោងជីកំប៉ុស្តិ៍
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់វិស័យឯកជន និងសាធារណៈ។

៤.៥.២- ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

ភូមិសាស្ត្រនិងសណ្ឋានដីជាខ្ពង់រាបនេះ ធ្វើឱ្យមានការលំបាកដល់ការគ្រប់គ្រងសំណល់រាវដែលចេញពីអគារលំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងរដ្ឋបាលសេវាសាធារណៈ នៃគម្រោងអភិវឌ្ឍក្រុងបូកគោ ប៉ុន្តែលំហូទឹកភ្លៀងមានទិសដៅច្បាស់លាស់ និងចាក់ចូលទៅក្នុងគន្លងដីដែលមានរយៈកម្ពស់ទាប ជាហេតុធ្វើឱ្យងាយនឹងលាយលំគ្នារវាងទឹកភ្លៀង និងទឹកកខ្វក់ និងប៉ះពាល់ដល់អាងស្តុកទឹកស្អាតសម្រាប់ផ្គត់ផ្គង់ដល់ក្រុង។ គម្រោងបានសិក្សារកទីតាំងដីចំនួន ៣ ទីតាំង ដែលមានទំហំសរុបប្រមាណ ១០០ ហិកតា សម្រាប់ធ្វើជាអាងប្រព្រឹត្តិកម្មទឹកកខ្វក់របស់ក្រុង។ ដូចនេះដើម្បីគ្រប់គ្រងសំណល់រាវឱ្យបានល្អ ត្រូវមានបទដ្ឋានបច្ចេកទេស និងយន្តការដូចខាងក្រោម÷

- អាជ្ញាធរក្រុង និងស្ថាប័នមានសមត្ថកិច្ចត្រូវគ្រប់គ្រង និងថែរក្សាឱ្យបានប្រភពធនធានទឹកធម្មជាតិ ដូចជា អូរ ប្រឡាយ អាងស្តុកទឹក បឹងធម្មជាតិ ផ្លូវទឹកផ្សេងៗ សម្រាប់ជាប្រព័ន្ធលូទឹកភ្លៀង អាងស្តុកទឹកជំនន់ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់តាមបច្ចេកទេសទំនើបដែលមានការអនុញ្ញាតពីក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ
- រៀបចំ និងកសាងប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងបរិស្ថាន មុននឹងបង្ហូរចូលបំពង់លូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់ សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្ម និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាព ដែលជាភារៈនៅទិសនិរតី។

៤.៥-៣. ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

ការបែងចែកតំបន់ប្រើប្រាស់ដី សម្រាប់ការការពារបរិស្ថានមានដូចខាងក្រោម÷

- តំបន់អភិវឌ្ឍនគរូបនីយកម្ម
- តំបន់កាពារនៃឧទ្យានជាតិព្រះមុនីវង្សបូកគោ
- តំបន់ទ្រនាប់ក្រុង
- តំបន់ធនធានទឹក រួមមាន អូរ ប្រឡាយ អាងស្តុកទឹក ស្ទឹង បឹង បណ្តាញផ្លូវទឹក
- តំបន់កសិកម្ម តាមរយៈជំរុញបង្កើតសួនបន្លែសេរីរាង្គ រក្សាអត្តសញ្ញាណម្ទេសបូកគោ ដំណាំតែ រុក្ខជាតិផ្កាបំពង់ឡោម និងរុក្ខជាតិធម្មជាតិច្រើនទៀត។

៤.៥.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារ និងថែរក្សាភ្នំ ព្រៃឈើ បឹង អូរ និងប្រព័ន្ធបណ្តាញផ្លូវទឹក ស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារ និងថែរក្សាព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន តាមរយៈការផ្គត់ផ្គង់អគ្គិសនីពីចំការអគ្គិសនីឱ្យបានច្រើនបំផុតក្នុងតំបន់ក្រុង
- ការលើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងតំបន់កណ្តាលក្រុង និងក្នុងទឹក
- លើកកម្ពស់ចំណេះដឹងបរិស្ថានដល់ប្រជាជន និងរៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាន ដោយមានការចូលរួមពីវិស័យឯកជន។

## ៤.៦-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

គម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស ដែលមានភូមិសាស្ត្រជាតំបន់ភ្នំ ខ្ពង់រាប និងជាប់មាត់សមុទ្រ ជាហេតុធ្វើឱ្យទីតាំងនេះ តែងតែទទួលរងគ្រោះរាំងស្ងួត ខ្យល់កន្ត្រាក់ និងអាកាសធាតុត្រជាក់ខ្លាំង។ ដូចនេះ ដើម្បីទប់ស្កាត់ផលប៉ះពាល់ពីគ្រោះមន្តរាយទាំងអស់នេះបានទាន់ពេលវេលា ត្រូវមានយន្តការ និងយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម÷

- ការពារធនធានធម្មជាតិ ជីវចម្រុះ ព្រៃឈើ និងតំបន់ឆ្នេរ ដើម្បីរក្សាបានតុល្យភាពបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ដោយមានការដាំដើមឈើឱ្យបានច្រើននៅតំបន់លម្ហសាធារណៈ និងតាមលំនៅឋាន
- ត្រូវរៀបចំប្រព័ន្ធរំដោះទឹកភ្លៀងដូចជា ស្ពានអូរ ប្រឡាយ បឹង ត្រពាំង រៀបចំទំនប់ទឹក អាងស្តុកទឹក និងបណ្តាញផ្លូវទឹកផ្សេងៗទៀត
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្រ្ទានព្រៃ
- រាល់គម្រោងអភិវឌ្ឍន៍ក្នុងតំបន់នេះចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្ការទប់ស្កាត់គ្រោះមហន្តរាយ
- លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឧទ្យានដោយសិក្សានិងរៀបចំផែនការប្រើប្រាស់ដី ឱ្យបានគ្រប់ជ្រុងជ្រោយ
- អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

## ៤.៧-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍន៍ក្រុង និងបរិស្ថាន ចាំបាច់ត្រូវ÷

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើង

- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ជាពិសេសសម្រាប់ការគ្រប់គ្រងអភិវឌ្ឍន៍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការចាក់ដី ការអភិវឌ្ឍដី និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានទីក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ រដ្ឋបាលខេត្តពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចខាងក្រោម÷

### ៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុង ត្រូវរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម ទាក់ទងនឹងការងារមួយចំនួនដូចខាងក្រោម÷

- ផែនទីព្រំប្រទល់ភូមិ សង្កាត់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធមានស្រាប់
- ផែនទីប្រើប្រាស់ដីបច្ចុប្បន្ន
- ផែនការប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ
- ប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗបន្តពីផែនការប្រើប្រាស់ដីរបស់ក្រុង
- ផែនទីកំណត់កម្ពស់អគារ និងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់
- ផែនទីកំណត់ទីតាំងលំហសាធារណៈ
- ផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព។

### ៥.២-ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោនេះ ដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ និងតាមរយៈគេហទំព័រ ឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្ត។

## ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុង ទេសចរណ៍ ការដឹកជញ្ជូន កសិកម្ម និងការផ្សព្វផ្សាយផលិតផល ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងគ្រប់គ្រងសំណល់រាវ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍ មានដូចខាងក្រោម÷

៥.៣.១- ការអភិវឌ្ឍក្រុង

- រៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធតំបន់គម្រោងអភិវឌ្ឍទាំង ៨ ទីតាំង តាមជំហាន ដូចជា ផ្លូវ ភ្លើង ស្ពាន ប្រព័ន្ធលូបង្ហូរទឹកភ្លៀង ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងសួនច្បារសាធារណៈ
- កសាងផែនការប្រើប្រាស់ដីលម្អិតរបស់គម្រោង និងប្លង់លម្អិតនគរូបនីយកម្ម
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ លើការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ធ្វើទំនប់ឬទ្វារទឹកសម្រាប់ទប់ទឹកចំនួន ២ ទីតាំង ដើម្បីរក្សាទឹកទុកប្រើប្រាស់
- ធ្វើផែនការអភិវឌ្ឍន៍ និងអភិរក្សតំបន់ការពារឧទ្យានជាតិព្រះមុនីវង្សបូកគោ
- កសាងផ្លូវមេតភ្ជាប់ពីផ្លូវជាតិលេខ៣ មកទីតាំងគម្រោងអភិវឌ្ឍក្រុងបូកគោ និងភ្ជាប់ទៅផ្លូវជាតិលេខ ៤ ចំនួន ២ ទីតាំង
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

៥.៣.២- ការអភិវឌ្ឍវិស័យទេសចរណ៍

- រៀបចំបទដ្ឋានគតិយុត្តគាំទ្រសំណង់ស្ថាបត្យកម្មលក្ខណៈខ្មែរ វប្បធម៌ សាសនា ដោយផ្សារភ្ជាប់នឹងទេសភាពវប្បធម៌ធម្មជាតិមានព្រៃឈើ សមុទ្រនិងភ្នំ
- ផ្សព្វផ្សាយផលិតផលទេសចរណ៍ រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិពរណ៍ផលិតផលក្នុងស្រុក
- រៀបចំផ្លូវទេសចរណ៍ សុវត្ថិភាព គុណភាពទេសចរណ៍ និងបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា
- អភិវឌ្ឍន៍ផលិតផលទេសចរណ៍ធម្មជាតិតាមព្រៃភ្នំ អភិវឌ្ឍការធ្វើដំណើរតាមខ្សែកាប ស្ពានយោលទេសចរណ៍ក្នុងព្រៃឈើ ដើម្បីគយគន់ព្រៃឈើ សមុទ្រ ព្រះអាទិត្យរះ-លិច ទេសភាពលំនៅឋាន ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងទឹកធ្លាក់
- រៀបចំសួនច្បារកម្សាន្ត និងទេសភាពធម្មជាតិ សម្រាប់ភ្ញៀវទេសចរ និងមនុស្សគ្រប់វ័យ
- បង្កើតចំការកង្ហារលើភ្នំសម្រាប់វិស័យថាមពល និងទស្សនាកម្សាន្ត
- អភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ និងសាសនា
- អភិវឌ្ឍទេសចរណ៍ទេសភាពតាមជម្រាលភ្នំ ការដាំដើមឈើ ផ្កា ការធ្វើកសិកម្ម
- អភិវឌ្ឍឱ្យមានស្ពាន និងផ្លូវសម្រាប់ដើរលម្ហែកាយ និងស្រូបខ្យល់អាកាសតាមព្រៃភ្នំ
- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍

- រៀបចំកម្មវិធីបុណ្យជាតិ និងព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍
- បណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។
- សាងសង់មណ្ឌលព័ត៌មានទេសចរណ៍
- ពង្រឹងភ្នាក់ងារគ្រប់គ្រង និងផ្តល់សេវាព័ត៌មានដល់ភ្ញៀវទេសចរ។

៥.៣.៣- ការដឹកជញ្ជូន

- កសាងផ្លូវភ្ជាប់ពីផ្លូវជាតិលេខ ៣ ទៅទីតាំងគម្រោងអភិវឌ្ឍក្រុងបូកគោ និងភ្ជាប់ទៅផ្លូវជាតិលេខ ៤
- សាងសង់រុក្ខវិថី ឬមហាវិថី វិថី អនុវិថី ផ្លូវចែលចាយក្នុងគម្រោងអភិវឌ្ឍក្រុង
- បន្តសាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០៣៥
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈ និងពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

៥.៣.៤- ការគ្រប់គ្រងបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលមូលនិធីពីសេវាកម្មធនធានធម្មជាតិ
- គ្រប់គ្រងនិងការពារឧទ្យានជាតិព្រះមុនីវង្ស។

៥.៣.៥- ការគ្រប់គ្រងសំណល់រឹង

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់
- ពង្រឹងក្រុមការងារតាមដាន និងត្រួតពិនិត្យការប្រមូលសំរាម
- ពង្រឹងក្រុមកម្មករសម្អាតគម្រោងអភិវឌ្ឍក្រុងបូកគោ
- រៀបចំសេចក្តីជូនដំណឹង និងដាក់ផ្ទាំងប៉ាណូកំណត់ពេលវេលាប្រមូលសំរាមតាមគោលដៅ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់តម្លៃសេវាប្រមូលសំរាមទីក្រុង តាមគោលការណ៍ណែនាំថ្មី
- អប់រំផ្សព្វផ្សាយអំពីសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីណែនាំស្តីពីការទុកដាក់ការពារសំណល់គ្រោះថ្នាក់

- ផលិតផ្ទាំងប៉ាណូអប់រំផ្សព្វផ្សាយ និងតាមវិទ្យុ
- ចុះធ្វើកិច្ចសន្យាគាំពារបរិស្ថានលើអាជីវកម្មពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ក្នុងក្រុង
- ចុះត្រួតពិនិត្យតាមដានលើអាជីវកម្មពាក់ព័ន្ធនឹងការបញ្ចេញសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីជូនដំណឹងអំពីការញែកសំរាម
- ផ្សព្វផ្សាយ និងណែនាំអំពីការញែកសំរាម សំណល់រឹង និងអនុវត្តជាក់ស្តែងដោយដាក់ធុងសំរាមក្នុងសាលាជាគំរូ
- អនុវត្តនូវវិធានការច្បាប់ និងផាកពិន័យ
- សហការជាមួយជំនាញដើម្បីផលិតខ្លឹមសារអប់រំបរិស្ថាន។

៥.៣.៦- ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ

- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន សំណង់អគារសេវាកម្មសាធារណៈ និងឯកជន ត្រូវរៀបចំអាងបង្គន់អនាម័យ និងអាងចម្រោះទឹកកខ្វក់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- រៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរដែលស្មើឡើង
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវធ្វើចម្រោះទឹក ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលទៅតំបន់ធនធានទឹក
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថានអនាម័យ។

៥.៣.៧- ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត

- ត្រួតពិនិត្យអ្នកប្រើប្រាស់បណ្តាញផ្គត់ផ្គង់ទឹកស្អាត
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកទាំងពីរទីតាំង
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹករហូតដល់ឆ្នាំ២០៣៥
- អភិវឌ្ឍធនធានទឹកផ្សេងទៀត
- អភិវឌ្ឍស្ថានីយ៍ចម្រោះទឹកស្អាត និងប្រព័ន្ធផ្គត់ផ្គង់ទឹកឱ្យបានមុនប្រជាជនមករស់នៅ។

៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍

- បំពាក់បណ្តាញផ្គត់ផ្គង់អគ្គិសនីដល់គម្រោងទាំង ៨ ទីតាំង
- ដំឡើងបណ្តាញអគ្គិសនីបំភ្លឺតាមដងវិថី
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យដល់តំបន់អភិវឌ្ឍក្រុង
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ជា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន
- បង្កើតចំការអគ្គិសនីសម្រាប់ជាប្រភពថាមពលអគ្គិសនីប្រកបដោយចីរភាពរបស់ក្រុង
- ពង្រីកបណ្តាញទូរគមនាគមន៍។

## ៥.៤-ការអនុវត្តផែនការរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម÷

៥.៤.១- ការអនុវត្តផែនការរយៈពេលខ្លី

- ផែនទីប្រើប្រាស់ដីបច្ចុប្បន្នក្រុង
- ផែនទីព្រំប្រទល់ភូមិ សង្កាត់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធក្រុង
- គម្រោងអាទិភាព
- ផែនការប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប៉ូកគោ ដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី និងសំណង់។

៥.៤.២- ការអនុវត្តរយៈពេលមធ្យម

គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

៥.៤.៣- ការអនុវត្តរយៈពេលវែង

- គម្រោងពង្រីកក្រុង ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជា បណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ទឹកភ្លៀង អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗ ស្របតាមស្ថានភាពភូមិសាស្រ្តជាក់ស្តែង មានជាអាទិ៍ តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លំហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍនាពេលអនាគត ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍបៃតង សំដៅធ្វើឱ្យទីក្រុងក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

## ៥.៥-គម្រោងអាទិភាព

- កសាងក្រុងឱ្យមានសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់
- កសាងសមត្ថភាពធ្វើផែនការក្រុង
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលទេសចរណ៍
- លើកកម្ពស់គុណភាពទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ ឯកជន
- អភិវឌ្ឍតំបន់ពាណិជ្ជកម្មឱ្យមានកន្លែងទុកដាក់សំរាម លូបង្ហូរទឹកកខ្វក់ ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ កន្លែងភៀវឡើងចុះរថយន្ត
- រៀបចំភ្លើងបំភ្លឺផ្លូវ ផ្លាកសញ្ញាទិសដៅចរាចរណ៍ សួនច្បារ និងផ្លូវថ្មើរជើងសម្រាប់អ្នកដំណើរ
- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលកសិកម្ម
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ

- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងទីប្រជុំជនក្រុង
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងក្របខណ្ឌគតិយុត្តជាធរមាន
- បង្កើតភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការគ្រប់គ្រងសំណល់រឹង និងរាវ
- អនុវត្តគោលគំនិត "ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ" សំណល់រឹង
- ការពារ និងថែរក្សាប្រវត្តិសាស្ត្រ ធម្មជាតិ ទេសភាព ភ្នំសមុទ្រ
- អភិរក្សធនធានធម្មជាតិ ដោយស្តារឡើងវិញនូវគម្របព្រៃឈើ
- ជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោមានជាអាទិ៍÷

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ២០៣៥ មាន÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្ត មាន÷ រដ្ឋបាលខេត្តពាក់ព័ន្ធ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តពាក់ព័ន្ធ មន្ទីរ អង្គភាពជំនាញ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

### ៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត មានជាអាទិ៍÷ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់

គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គិរីរម្យ" គោលនយោបាយដីធ្លី (សៀវភៅសដីធ្លី) គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលខេត្តពាក់ព័ន្ធ ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការ មានភារកិច្ច៖

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ៥ ឆ្នាំ កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល ៥ ឆ្នាំម្តង ស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដី និងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយ **ឈ្នះ-ឈ្នះ** និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវបានរៀបចំឡើង និងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោលដ៏មានសារៈសំខាន់ សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣៥ គឺ **«ភ្នំបូកគោ ជាក្រុងឆ្លាតវៃ ទេសចរណ៍ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា»** តាមរយៈការជំរុញ ÷ ១).កំណត់គោលនយោបាយ និងបទដ្ឋានគតិយុត្តបង្កើតជាក្រុង សម្រាប់លំនៅឋាន សម្រាកលំហែកម្សាន្ត សិក្សា ការងារ និងធុរកិច្ច ប្រកបដោយសុខភាព គុណភាពបរិស្ថានល្អ និងជាទិសដៅទេសចរណ៍ដ៏ប្រណីតកម្រិតខ្ពស់ សម្រាប់ការទាក់ទាញ និងប្រកួតប្រជែងក្នុងតំបន់និងអន្តរជាតិ ២).ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ថែរក្សាប្រភពទឹកធម្មជាតិ ទេសភាព និងអាកាសធាតុភ្នំ-សមុទ្រ ៣).កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន លំហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសមាហរណកម្មតភ្ជាប់ក្នុងតំបន់ ៤).ទាក់ទាញលើកទឹកចិត្ត និងគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន ដើម្បីអភិវឌ្ឍធុរកិច្ច អភិវឌ្ឍផលិតផលទេសចរណ៍សម្បូរបែបប្រកបដោយគុណភាពខ្ពស់ និងជំរុញកំណើនសេដ្ឋកិច្ច និង ៥).អភិបាលកិច្ចល្អ និងអភិវឌ្ឍធនធានមនុស្ស និងដើម្បីរួមចំណែកអភិវឌ្ឍន៍និងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្តតាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជំរុញការផ្សព្វផ្សាយ និងអនុវត្តន៍តាមប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីធានាការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ហើយត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ឯកសារឧបសម្ព័ន្ធ

- ផែនទីប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥
- ផែនទីបណ្ដាញផ្លូវសំខាន់ៗនៃគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥
- ផែនទីឧទ្យានជាតិព្រះមុនីវង្ស "បូកគោ"
- ផែនទីតំបន់ការពារក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ
- ផែនទីរូបថតពីលើអាកាសគម្រោងអភិវឌ្ឍក្រុងបូកគោ
- គម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

# ផែនទីប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ២០៣៥

ឧបសម្ព័ន្ធអនុក្រឹត្យលេខ...........ចុះថ្ងៃ..........ខែ..........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦...... ត្រូវនឹងថ្ងៃទី..........ខែ..........ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ










## និយាមកាតីបង់ឧទ្យានជាតិព្រះមុនីវង្ស បូកគោ

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| A | 402810 | 1168653 | N | 394181 | 1227998 |
| B | 400650 | 1168148 | O | 396796 | 1232460 |
| C | 395184 | 1171052 | P | 395566 | 1236924 |
| D | 387286 | 1171587 | Q | 402616 | 1238796 |
| E | 384045 | 1174392 | R | 404316 | 1232325 |
| F | 378487 | 1187086 | S | 406537 | 1231627 |
| G | 377158 | 1195536 | T | 408004 | 1225468 |
| H | 379176 | 1205847 | U | 408004 | 1215883 |
| I | 384777 | 1209233 | V | 403996 | 1210001 |
| J | 383146 | 1220836 | W | 404999 | 1197997 |
| K | 390001 | 1228888 | X | 408869 | 1180152 |
| L | 390000 | 1231510 | Y | 404933 | 1173146 |
| M | 392423 | 1231605 | Z | 405501 | 1170055 |

១.ឯកឧត្តម ប៉ែន សុផល រដ្ឋលេខាធិការ — ប្រធាន
២.ឯកឧត្តម — អនុរដ្ឋលេខាធិការ — អនុប្រធាន
៣.ឯកឧត្តម — អគ្គលេខាធិការរង — អនុប្រធាន
៤.ឯកឧត្តម — អគ្គលេខាធិការរង — សមាជិក
៥.លោក — ប្រធានការិយាល័យបច្ចេកទេស — សមាជិក
៦.លោក — អនុប្រធានការិយាល័យបច្ចេកទេស — សមាជិក

មាត្រដ្ឋាន ១:៧០ ០០០

6 3 0 គ.ម 6